លេខ ៤៥ ស.រ ភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆកា ឆ្នាំ១៩៨២

# សារាចរណែនាំ

# ស្តីពី

# លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើស

# អ្នកការពារអមតុលាការប្រជាជន

# និង

# របៀបធ្វើបញ្ជីរាយនាមអ្នកការពារ

បក្ស និង រដ្ឋ របស់យើង តែងតែចាប់អារម្មណ៍ជានិច្ចចំពោះដំណើរការ ដ៍ល្អប្រពៃ នៃអង្គការតុលាការ និង ចំពោះការគោរពសិទ្ធិជាមូលដ្ឋាន នៃប្រជាជន ជាពិសេស សិទ្ធិប្តឹងរកយុត្តិធម៌ និង សិទ្ធិការពារបុព្វហេតុស្របច្បាប់របស់ពលរដ្ឋ នៅចំពោះមុខតុលាការ។

មាត្រា ៩ នៃច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និង អយ្យការ ដែលប្រកាសឱ្យប្រើតាម ក្រឹត្យលេខ ២០ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ១៩៨២ បានចែងជាអាទិ៍ថា ជនជាប់ចោទ មានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងមេធាវីណាមួយ ឬ អ្នកដទៃណាមួយ ឱ្យជួយការពារ ក្នុងរឿងសំខាន់តុលាការ ត្រូវចាត់តាំងមេធាវី ឬ អ្នកការពារឬ ឱ្យជួយការពារជនជាប់ចោទ បើជនជាប់ចោទ គ្មានលទ្ធភាពនឹងពឹងអ្នកការពារឱ្យ ជួយការពារបាន...។ ប៉ុន្តែ បញ្ហានេះ បានចោទខ្លាំងចំពោះយើង ដោយហេតុថា នៅក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត , អៀង សារី,ខៀវ សំផន មេធាវីពេញសិទ្ធិទាំងឡាយ ត្រូវបានពួកវាកាប់សម្លាប់ផុតពូជ។ ហេតុដូច្នេះហើយ បានជា បច្ចុប្បន្ននេះ យើងពុំអាចបង្កើតឱ្យទាន់ពេលវេលានូវសមាគមមេធាវី ដែលអាចការពារផលប្រយោជន៍ភាគីក្នុងរឿងក្តីនានាបាន។ ប៉ុន្តែ ដើម្បីនឹងបំពេញ ការខ្វះខាតនេះ គណៈកម្មាធិការ រណសិរ្សសាមគ្គី (កសាងការពារមាតុភូមិ ខេត្ត ឬ ក្រុងនីមួយៗ ត្រូវរៀបចំជ្រើសរើស និង ធ្វើបញ្ជីរាយនាមអ្នកការពារ អមតុលាការប្រជាជន ស្របបមាត្រា ២៦ នៃច្បាប់ខាងលើនេះ

## I - សិទ្ធិ និង ភារកិច្ចរបស់អ្នកការពារ

អ្នកការពារមានសិទ្ធិដូចតទៅ៖

- សិទ្ធិប្រើគ្រប់មធ្យោបាយដែលច្បាប់ទទួលស្គាល់ ដើម្បីការពារភាគី ដែលបានពឹងខ្លួន

- សិទ្ធិពិនិត្យដោយហ្មត់ចត់លើគ្រប់ទិដ្ឋភាពនៃសំណុំរឿង ហើយអ ាចកត់ តទុកបានទូវទិដ្ឋភាពនោះ ប្រសិនបើយល់ថាចាំបាច់

- សិទ្ធិទាក់ទងជាមួយជនជាប់ចោទក្នុងពន្ធនាគារ ដោយគ្មានវត្តមាននៃតតិយជន ប្រសិនបើអ្នកការពារនោះ ជាអ្នកការពារជនជាប់ចោទ

- សិទ្ធិធ្វើសំណើ សិទ្ធិចូលរួមក្នុងសវនាការ សិទ្ធិតាំងសំនួរដល់ជនជាប់ចោទ ដល់ជនរងគ្រោះ ដល់សាក្សី និង ដល់ជនដទៃទៀត ដែលចូលរួមក្នុងនីតិវិធីព្រហ្មទណ្ឌ

- សិទ្ធិបញ្ចេញការកត់សំគាល់ តបនឹងការប្រព្រឹត្តិរបស់រដ្ឋអាជ្ញា ឬ សមាជិកណាមួយ នៃក្រុមប្រឹក្សាជំនុំជំរះ ដែលផ្ទុយនឹងច្បាប់នីតិវិធីព្រហ្មទណ្ឌ អ្នកការពារមានកាតព្វកិច្ច ដូចតទៅ ៖

- ត្រូវគោរពគោលនយោបាយ របស់បក្សប្រជាជនបដិវត្តកម្ពុជា

- ត្រូវចៀសវាងកុំក្លែងការពិត

- ត្រូវកុំនិយាយអ្វី ដែលផ្ទុយនឹងសម្បជញ្ញៈ របស់ខ្លួន ហើយចៀសវាងកុំពោលពាក្យប្រមាថ ឬ ពាក្យបរិហាកេរ្តិ៍ ចំពោះភាគីតតិយជន ឬ រដ្ឋអំណាច

- អ្នកការពារ មិនអាចបោះបង់ការ ការពាររបស់ខ្លួនបានឡើយ កាលបើខ្លួនបានយល់ព្រមបំពេញភារកិច្ចនោះហើយ។

## II - **លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសអ្នកការពារ**

ដើម្បីធ្វើជាអ្នកការពារបាន ពលរដ្ឋទាំងពីរភេទ ត្រូវមានលក្ខណៈដូចតទៅៈ

- មានអាយុច្រើនជាង ២១ឆ្នាំ

- មានប្រវត្តិរូបច្បាស់លាស់

- សកម្មភាពក្នុងការងារ ទាំងខាងការកសាង ទាំងខាងការការពារមាតុភូមិ

- ជាជនគំរូក្នុងការអនុវត្តន៍ច្បាប់រដ្ឋធម្មនុញ្ញ និង មាគ៌ានយោបាយរបស់បក្សប្រជាជនបដិវត្តកម្ពុជា

- មានជីវភាពរស់នៅស្អាតស្អំ គោរពសីលធម៌បដិវត្តន៍

- រស់នៅជាមួយប្រជាជន មានប្រជាជនស្រឡាញ់រាប់អាន និង គាំទ្រច្រើន ម្យ៉ាងទៀត ដើម្បីការពារប្រយោជន៍ដ៏ឧត្តមរបស់ពលរដ្ឋនៅក្នុងរឿងក្តីឱ្យរឹងរឹតតែបានប្រសើរថែមទៀតនោះ គប្បីជ្រើសរើសជនណាដែលជាអ្នកមានវោហារ វៃឆ្លាត ឬ ជាអ្នកដែលមានវិជ្ជាទូទៅគ្រប់គ្រាន់។

## III - **របៀបធ្វើបញ្ជីរាយនាមអ្នកការពារ**

មាត្រា ២៦ នៃច្បាប់ស្តីពី ការចាត់តាំងអង្គការតុលាការ និង អយ្យការ បានបញ្ជាក់ថា បញ្ជីរាយនាមអ្នកការពារត្រូវធ្វើឡើងដោយគណៈកម្មាធិការ រណសិរ្សសាមគ្គី កសាង ការពារមាតុភូមិ ខេត្ត ឬ ក្រុង ដោយសហការជាមួយ សហជីពកម្ពុជា យុវជនបដិវត្តកម្ពុជា និង សមាគមនារីកម្ពុជា ខេត្ត ឬ ក្រុងនោះ។

ជាបឋម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចេញប្រកាសកំណត់ចំនួនអ្នកការពារអមតុលាការប្រជាជន ខេត្ត ឬ ក្រុង។

កាលបើបានទទួលប្រកាសខាងលើនេះហើយ គណៈកម្មាធិការរណសិរ្ស សាមគ្គី កសាង ការពារមាតុភូមិ ក្រុង ឬ ខេត្ត នីមួយៗ ត្រូវរៀបចំបើកអង្គប្រជុំមួយ ដោយមានអញ្ជើញតំណាងគ្រប់អង្គការមហាជនថ្នាក់ស្មើឱ្យចូលរួម។

ប្រធានតុលាការប្រជាជន ឬ តំណាង ក៏អាចអញ្ជើញឱ្យចូលរួមដែរ ដើម្បីឧទ្ទេសនាមអំពីតួនាទី និងភារកិច្ចរបស់អ្នកការពារ និង អំពីខ្លឹមសារនៃច្បាប់ ស្តីពី ការចាត់តាំងអង្គការតុលាការ និងអយ្យការ។ ប្រធានគណៈកម្មាធិការរណសិរ្ស សាមគ្គី កសាង ការពារមាតុភូមិ ខេត្ត ឬ ក្រុង ឡើងបញ្ជាក់អំពីលក្ខណសម្បត្តិ ដែលអ្នកការពារម្នាក់ៗ ត្រូវមាន ហើយស្នើឱ្យគ្រប់អង្គការមហាជន ធ្វើសំណើ ផ្ញើអ្នកគណៈកម្មាធិការរណសិរ្ស សាមគ្គី កសាង ការពារមាតុភូមិ ខេត្ត ឬ ក្រុង ឱ្យទាន់ពេលវេលា។ បន្ទាប់មក អង្គការមហាជនផ្នែកនីមួយៗ ( សហជីព យុវជនបដិវត្ត សមាគមនារី) ត្រូវបើកសម័យប្រជុំក្នុងក្របខ័ណ្ឌរបស់ខ្លួន ដើម្បីធ្វើបញ្ជីស្នើជន ដែលអង្គការមហាជននោះយល់ឃើញថា មានលក្ខណសម្បត្តិ អាចទទួលនាទីជាអ្នកការពារបាន ហើយដោយបានការយល់ព្រមពីសាមីជនផង។ ចំនួនជនដែលស្នើ ត្រូវឱ្យមានច្រើនជាងចំនួនអ្នកការពារ ដែលត្រូវជ្រើសតាំង។

កាលបើបានទទួលបញ្ជីសំណើ ពីគ្រប់កន្លែងមកហើយ គណៈកម្មាធិការ រណសិរ្សសាមគ្គី កសាង ការពារមាតុភូមិ ខេត្ត ឬ ក្រុង ត្រូវបើកសម័យប្រជុំ លើកទី ២ ម្តងទៀត ដើម្បីធ្វើបញ្ជីរាយនាមសំរេចជាស្ថាពរ។

ប្រធានគណៈកម្មាធិការរណសិរ្សសាមគ្គី កសាង ការពារមាតុភូមិ ខេត្ត ក្រុង មានភារកិច្ចឱ្យដំណឹងទេសាមីខ្លួន និង បញ្ជូនបញ្ជីរាយនាមអ្នក ការពារ ទៅឱ្យតុលាការប្រជាជនខេត្ត ឬ ក្រុង។

ជាចុងក្រោយបង្អស់ ប្រធានតុលាការប្រជាជន ត្រូវអញ្ជើញអ្នកការពារ ទាំងអស់ មកបំពាក់បំប៉នខាងផ្នែកការងារតុលាការ មុននឹងឱយអ្នកការពារទាំង អស់នោះ ចូលបំពេញការងារ ។

ក្នុងករណីដែលមានអ្នកការពារម្នាក់ ឬ ច្រើននាក់ ឈប់ពីមុខតំណែង គណៈកម្មាធិការរណសិរ្សសាមគ្គី កសាង ការពារមាតុភូមិខេត្ត ឬ ត្រូវធ្វើបញ្ជីរាយនាមអ្នកការពារបន្ថែបបង្គ្រប់ តាមសំណើរបស់តុលាការប្រជាជនខេត្ត ឬ ក្រុងនោះ។

រីឯរបៀបធ្វើបញ្ជីបន្ថែ ក៏ត្រូវអនុវត្តដូចការណែនាំខាងលើនេះដែរ។

កាលបើសមមិត្ត ជួបការលំបាកក្នុងការអនុវត្តន៍ ខ្ទះសារាចរនេះ ស្នើសមមិត្តសួរមតិក្រុមប្រឹក្សារដ្ឋមន្ត្រី ឬ មកក្រសួងយុត្តិធម៌។

## IV - **ដំណើរការអនុវត្តន៍**

ក្រសួងយុត្តិធម៌ គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុង ផ្អែកតាម តួនាទីរបស់ខ្លួន ចាត់តាំង និងអនុវត្តសារាចរ ឱ្យទទួលបានលទ្ធផលល្អប្រសើរ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

**ចាន់ ស៊ី**

ចម្លងជូន៖

-ក្រសួងយុត្តិធម៌

-គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង

ដើម្បីអនុវត្ត

-ក្រុមប្រឹក្សារដ្ឋ

-ក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្សសាមគ្គី

កសាង ការពារមាតុភូមិ កម្ពុជា

-គណៈចាត់តាំងមជ្ឈិម

ដើម្បីជ្រាបជាពត៌មាន

-ឯកសារ